ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ...៨១...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការកាត់ផ្ទៃដីក្រហមពីដែនព្រៃសម្បទានសំរាប់ចំការកៅស៊ូ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៥ ក្រច ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការគ្រប់គ្រងវិស័យព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សំរេច

**មាត្រា ១** : ត្រូវបានកាត់ផ្ទៃដីក្រហមចំនួន ៦.២០០ ហិកតា ចេញពីដែនព្រៃសម្បទានដែលក្នុងនោះផ្ទៃដីរបស់ក្រុមហ៊ុន ហ្គេត ចំនួន ២.១៨១ ហិកតា សហគ្រាសកូឡិចស៊ីមចំនួន ៣.៥៧៧ ហិកតា និងក្រុមហ៊ុន មៀង លីហេង ចំនួន ៤៤២ ហិកតា ដែលស្ថិតនៅក្នុងឃុំទីរឹង ស្រុកសណ្តាន់ ខេត្តកំពង់ធំ ដូចមានផែនទីបញ្ជាក់ទីតាំងជាឧបសម្ព័ន្ធជូនភ្ជាប់ ។

**មាត្រា ២** : ដីក្រហមនេះត្រូវប្រគល់អោយ :

- ប្រជាជនកំពុងកាន់កាប់ចំនួន ៩១២ ហិកតា
- ទុកបំរុងចែកជូនប្រជាជនសំរាប់ដាំកៅស៊ូជាលក្ខណ:គ្រួសារចំនួន ៩២៩ ហិកតា
- ចំការកៅស៊ូជុប សំរាប់ដាំកៅស៊ូជាលក្ខណ:ឧស្សាហកម្មចំនួន ៤.៣៥៩ ហិកតា ។

**មាត្រា ៣** : ចំការកៅស៊ូជុប មានភារកិច្ចផ្តល់ជូនប្រជាជននូវសេវាបច្ចេកទេសក្នុងការដាំដុះ ការថែទាំរហូតដល់ការប្រមូលផល ។

**មាត្រា ៤** : ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ត្រូវធ្វើការវាស់វែងជាក់ស្តែង និង រៀបចំធ្វើប្លង់កម្មសិទ្ធិកាន់កាប់ដីធ្លីជូនប្រជាជន និង ចំការកៅស៊ូជុប ។

**មាត្រា ៥** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីរដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *ឯកសារ_កាលប្បវត្តិ*